February-2010.qxd 2/3/2010 10:44 AM Page 9



# បវរកញ្ញាមីន : "បើកាយពិការទៅហើយ សូមកុំពិការចិត្ត"

**ខាន់ ភីរម្យ**

*ក្រោយសង្គ្រាមអស់រយៈពេល៣០ឆ្នាំ កម្ពុជាគឺជាប្រទេសសម្បូរមីនមួយនៅលើពិភពលោក ហើយក៏មានជនពិការច្រើនដោយសារតែគ្រាប់មីន។ ដើម្បីយល់អំពីការលំបាក និងការតស៊ូក្នុងជីវិតពិការ អ្នកនាំសារ សូមណែនាំមិត្តអ្នកអានឱ្យស្គាល់កញ្ញាដុះ សុភាព ជាបវរកញ្ញាមីន។*



Photo : DR

កញ្ញាដុះ សុភាព បវរកញ្ញាមីនឆ្នាំ២០០៩

**អ្នកនាំសារ : តើកញ្ញាមានអាយុប៉ុន្មាន? ហើយមូលហេតុអ្វីបានជាកញ្ញាពិការ?**

**កញ្ញាដុះ សុភាព :** ចាស៎ ! ខ្ញុំមានអាយុ ១៩ឆ្នាំបច្ចុប្បន្ន ខ្ញុំគឺជាសិស្សវិទ្យាល័យសម្តេចឪ ក្នុងក្រុងបាត់ដំបង ។ ខ្ញុំអត់ចាំថា ខ្ញុំពិការដោយសារអ្វី? និងអាយុប៉ុន្មានដែរ? ។ ប៉ុន្តែម៉ាក់ខ្ញុំប្រាប់ថា ខ្ញុំធ្លាក់ខ្លួនពិការ តាំងពីអាយុ ៦ឆ្នាំ នៅពេល ដែលខ្ញុំទៅលេងឪពុកខ្ញុំដែលធ្វើជាទាហាននៅស្រុកបវិល ។

**អ្នកនាំសារ : តើមូលហេតុអ្វីបានជាកញ្ញាសម្រេចចិត្តដាក់ពាក្យចូលរួមក្នុងការប្រកួតបវរកញ្ញាមីននៅកម្ពុជាកាលពីឆ្នាំ២០០៩ទៅនេះ?**

**កញ្ញាដុះ សុភាព :** ដំបូងខ្ញុំក៏ស្ទាក់ស្ទើរដែរក្នុងការបង្ហាញគេថា ខ្ញុំជាជនពិការមួយរូប តែក្រោយមកខ្ញុំសម្រេចចិត្តចូលរួមដើម្បីបង្ហាញអំពីភាពក្លាហានរបស់ខ្ញុំក្នុងនាមជាជនពិការមួយរូប ។

**អ្នកនាំសារ : តើកញ្ញាជួបការលំបាកយ៉ាងណាសម្រាប់ឆាកជីវិតជាជនពិការ ហើយតើធ្លាប់មានអារម្មណ៍តូចចិត្តនឹងខ្លួនឯងដែរឬទេ?**

**កញ្ញាដុះ សុភាព :** ខ្ញុំមិនចាំទេកាលពីនៅតូច ។ ប៉ុន្តែចាប់តាំងពីខ្ញុំដឹងក្តីពេលណាមក ខ្ញុំតែងតែមានអារម្មណ៍តូចចិត្តនឹងខ្លួនឯងជានិច្ច ។ រស់នៅជា ជនពិការមិនជារឿងដែលងាយស្រួលទេ ។ ដំបូងខ្ញុំត្រូវប្រឈមនឹងការបង្អាប់ពីមិត្តភក្តិ ហើយសូម្បីតែបងប្អូនបង្កើតក៏មានម្តងម្កាលដែរ ។ ប៉ុន្តែខ្ញុំយល់ថា បើយើងពិការទៅហើយ និងរវល់តែតូចចិត្តនោះ តើវាមានប្រយោជន៍អ្វី?

**អ្នកនាំសារ : តើសព្វថ្ងៃកញ្ញាមានមុខរបរធ្វើអ្វី? ហើយតើកញ្ញាអាចធ្វើអ្វីបាននៅក្នុងគ្រួសារ?**

**កញ្ញាដុះ សុភាព :** ខ្ញុំក៏ជាសិស្សថ្នាក់ទី១២ មួយរូប ហើយកំពុងតែត្រៀមខ្លួនប្រឡងដើម្បីសម្រេចគោលបំណងរបស់ខ្ញុំទៅថ្ងៃអនាគត ដែលចង់ធ្វើជាគណនេយ្យករ ឬក៏អ្នករដ្ឋបាលមួយរូបនឹងគេ ។ នៅក្នុងគ្រួសារ ថ្វីត្បិតតែខ្ញុំពិការ តែខ្ញុំនៅតែអាចជួយកិច្ចការគ្រួសារខ្លះៗដូចជា ដាំបាយ លាងចានជំនួសដៃជើងប៉ាម៉ាក់របស់ខ្ញុំបានខ្លះដែរ ។

**អ្នកនាំសារ : តើកញ្ញាចូលចិត្តរៀនមុខវិជ្ជាអ្វីនិងទទួលបានចំណាត់ថ្នាក់យ៉ាងណាដែរក្នុងសាលា?**

**កញ្ញាដុះ សុភាព :** ខ្ញុំចូលចិត្តរៀនមុខវិជ្ជាសីលធម៌ ប្រវត្តិវិទ្យា ភូមិវិទ្យា ហើយនិងអក្សរសាស្ត្រខ្មែរ ។ ក្នុងថ្នាក់ ខ្ញុំរៀនជាប់ចំណាត់ថ្នាក់លេខ១២ ។

**អ្នកនាំសារ : តើកញ្ញាមានចំណាប់អារម្មណ៍ចង់ផ្តាំផ្ញើអ្វីខ្លះទេទៅកាន់មិត្តភក្តិរបស់កញ្ញា ហើយក៏ដូចជាជនពិការទាំងឡាយនៅក្នុងប្រទេស?**

**កញ្ញាដុះ សុភាព :** ខ្ញុំមិនមានអ្វីសំខាន់ទេ តែអ្វីដែលខ្ញុំចង់ផ្តាំផ្ញើទៅមិត្តភក្តិរបស់ខ្ញុំនោះគឺថា សូមកុំមើលងាយជនពិការ ហើយត្រូវជួយលើកទឹកចិត្តជនពិការ ហើយក៏សូមប្រាប់ទៅជនពិការទាំងអស់ថា បើយើងពិការហើយ សូមកុំអស់សង្ឃឹមនៅក្នុងជីវិត ត្រូវមានការតស៊ូតទៅទៀត ហើយកុំស្តាប់ ឬខូចអារម្មណ៍ នៅពេលដែលគេបង្អាប់ ។ យើងត្រូវតែតស៊ូឡើងជានិច្ច ។ "បើយើងធ្លាក់ខ្លួនពិការរាងកាយ ហើយ ក៏សូមកុំពិការចិត្តទៀត" ។



Photo : DR

**កញ្ញាដុះ សុភាព បវរកញ្ញាមីន ថតរូបអនុស្សាវរីយ៍ជាមួយក្រុមគ្រួសារ។ នេះគឺជាសេចក្តីក្លាហានរបស់ជនពិការដែលហានប្រឈមមុខនឹងការពិតតាមរយៈការបញ្ចេញសមត្ថភាពនៅក្នុងសង្គម។**

### បវរកញ្ញាមីននៅកម្ពុជា

កញ្ញាដុះ សុភាព បានជាប់ការជ្រើសរើសបវរកញ្ញាមីននៅក្នុងប្រទេសកម្ពុជា នាឆ្នាំ២០០៩ កន្លងទៅនេះ។ កញ្ញាអះអាងថា: "ខ្ញុំសប្បាយចិត្តណាស់ដែលជាប់ការជ្រើសរើសនេះ ហើយក៏មិននឹកថា ខ្ញុំពិការហើយ នៅមានឱកាសបែបនេះទេ"។

កញ្ញាសុភាព គឺជាយុវសិស្សនៅវិទ្យាល័យសម្តេចឪក្រុងបាត់ដំបង ហើយជាកូនស្រីទី២នៅក្នុងគ្រួសារដែលមានកូនប្រុស២ និងស្រី៣នាក់។ ឪពុកនាងគឺជាអតីតទាហាន ហើយម្តាយគឺជាមេផ្ទះ។ កញ្ញាគឺជាបេក្ខនារីមួយរូបនៅក្នុងចំណោមបេក្ខនារី ២០រូប ដែលបានចុះឈ្មោះប្រឡងបវរកញ្ញាមីនប្រចាំឆ្នាំ២០០៩ តាមរយៈរូបថតដោយអ្នកសិល្បៈជនជាតិន័រវេស្ស ឈ្មោះ ម៉រថេន ប្រារិក។